# ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា
## CAMBODIA WATCHDOG COUNCIL INTERNATIONAL

ទីក្រុងគ្រីស្ទានសាន់ ថ្ងៃទី២១ ខែមករា ឆ្នាំ២០២១

# សេចក្តីថ្លែងការណ៍
## តើពន្លឺយុត្តិធម៌នៅឯណា សម្រាប់លោក ជា វិជ្ជា រយៈពេល ១៧ឆ្នាំមកនេះ?

លោក **ជា វិជ្ជា** ជាមេដឹកនាំសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា និងជាសមាជិកស្ថាបនិកនៃក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា ត្រូវបានឃាតកបាញ់សម្លាប់ កាលពីថ្ងៃទី ២២ ខែមករា ឆ្នាំ២០០៤ ជាឃាតកម្ម មានជាប់ពាក់ព័ន្ធនឹងលោក **ហុក ឡុងឌី** មេប៉ូលីសជាតិនៃក្រសួងមហាផ្ទៃ និងជាដន្លងរបស់លោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន**។

**ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា** កត់សម្គាល់ឃើញថាលោក **ហេង ពៅ** អតីតស្នងការនគរបាលរាជធានីភ្នំពេញ ដែលបច្ចុប្បន្នកំពុងជាប់ពន្ធនាគារ **គឺជាសាក្សីយ៉ាងសំខាន់បំផុត** ក្នុងសំណុំរឿងលោក **ជា វិជ្ជា**។ ក្រៅពីនេះ នៅមានមន្ត្រីប៉ូលីសមួយចំនួនទៀត ក៏មានពាក់ព័ន្ធក្នុងសំណុំរឿងសម្លាប់លោក **ជា វិជ្ជា** ក្រោមអំណាចបញ្ជារបស់លោក **ហុក ឡុងឌី** កាលនោះ។

កាលនៅរស់ លោក **ជា វិជ្ជា** ត្រូវបានគេគំរាមសម្លាប់ នៅខែសីហា ឆ្នាំ២០០៣ តាមសារជាអក្សរផ្ញើចូលទូរស័ព្ទរបស់លោក ដែលជាលេខទូរស័ព្ទរបស់មន្ត្រីប៉ូលីសជាន់ខ្ពស់នៃ ក្រសួងមហាផ្ទៃ។ ពេលនោះលោក **ជា វិជ្ជា** ក៏ធ្លាប់និយាយប្រាប់ពួកយើងខ្ញុំ ជាមិត្តជិតស្និទ្ធផង និងជាក្រុមការងារនៃ**ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា** ដោយបញ្ជាក់ទាំងទឹកមុខស្លុតថា ***«មន្ត្រីជាន់ខ្ពស់ពីក្រសួងមហាផ្ទៃ នៅក្រោមបញ្ជាមេប៉ូលីសកំពូល គំរាមសម្លាប់ខ្ញុំ»***។

សំណុំរឿងនេះ នៅតែមិនទាន់អាចរកពន្លឺយុត្តិធម៌បាននៅឡើយ មកទល់សព្វថ្ងៃ។ ដោយឡែក ការធ្វើមិនដឹងមិនឮរបស់លោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ក្នុងសំណុំរឿងឃាតកម្មលោក **ជា វិជ្ជា** នេះ **បានធ្វើឲ្យពលរដ្ឋខ្មែរ មានមន្ទិលសង្ស័យពីការរួមគំនិត ឬគប់គិតណាមួយ ក្នុងផែនការសម្លាប់លោក ជា វិជ្ជា** ដើម្បីព្រមានដោយប្រយោលដល់គណបក្សសម្ព័ន្ធភាពប្រជាធិបតេយ្យជាប់ឆ្នោត ២ ទៀត គឺបក្សហ្វ៊ុនស៊ិនប៉ិចរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** និងបក្សសមរង្ស៊ីរបស់លោក **សម រង្ស៊ី** ដែលធ្វើឲ្យជាប់គាំងនយោបាយជិត ១ឆ្នាំ តាំងពីក្រោយការបោះឆ្នោតជាតិ នៅខែកក្កដា ឆ្នាំ២០០៣ រហូតដល់ខែឧសភា ឆ្នាំ២០០៤ ទើបមានដំណោះស្រាយនយោបាយបាន **ស្របតាមរដ្ឋធម្មនុញ្ញ រូបមន្ត ២ ភាគ ៣ ក្នុងការបង្កើតរដ្ឋាភិបាលថ្មី**។

**យើងខ្ញុំសូមរំលឹកថា** ក្នុងចំណោមអង្គការជាសមាជិកនៃ **ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា** (៦ អង្គការ សមាគម និងសហជីព ជាសមាជិក) មានតែសហជីពរបស់លោក **ជា វិជ្ជា** ដែលមានកម្លាំងកម្មករច្រើនជាងគេបំផុត គាំទ្រវាល់ការព្រមានរបស់ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា និងគណបក្សសម្ព័ន្ធភាពប្រជាធិបតេយ្យ **នាំមុខដឹកនាំមហាបាតុកម្មប្រឆាំងលទ្ធផលនៃការបោះឆ្នោតជាតិ** ខែកក្កដា ឆ្នាំ២០០៣ និង **មិនទទួលស្គាល់បេក្ខភាពលោក ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី បន្តនៅអាណត្តិថ្មីទៀត។

**ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា** សូមអំពាវនាវយ៉ាងទទូចថា ដើម្បីជម្រះមន្ទិលសង្ស័យនានា និងបំបាត់អំពើនិទណ្ឌភាព រដ្ឋាភិបាលលោក **ហ៊ុន សែន** និងតុលាការកម្ពុជា ត្រូវជំរុញការស៊ើបអង្កេតឲ្យសកម្ម រួចផ្តល់យុត្តិធម៌ជូនសាច់ញាតិ ក្រុមគ្រួសារ និងអ្នកគាំទ្រលោក **ជា វិជ្ជា** ជានិមិត្តរូបនៃការពង្រឹងនូវប្រព័ន្ធយុត្តិធម៌ថ្លៃថ្នូរ ការអនុវត្តច្បាប់ជាក់លាក់ និងនីតិរដ្ឋស្អាតស្អំ។

ប្រធានក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា

ម៉ែន ណាត

Address: Senterveien 54, Apartment 112, 4790 Lillesand, NORWAY /Contact: nathamonin@gmail.com
Hompage: https://cwcicambodia.net